ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# កំពង់រទេះ
# សម្រាប់រយៈពេល ៣ ឆ្នាំ
# (កក្កដា ២០១៩ - មិថុនា ២០២២)

17

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | កំពង់រទេះ |
| ភូមិ | ៖ | កំពង់រទេះ |
| ឃុំ | ៖ | បឹងចារ |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

ខែមករា ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# កំពង់រទេះ
# សម្រាប់រយៈពេល ៣ ឆ្នាំ
# ( កក្កដា ២០១៩ - មិថុនា ២០២២ )

17

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | កំពង់រទេះ |
| ភូមិ | ៖ | កំពង់រទេះ |
| ឃុំ | ៖ | បឹងចារ |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

ខែមករា ឆ្នាំ២០១៩

# មាតិកា


១. ស្ថានភាពទូទៅ ............ ១
២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ............ ២
ក. ប្រជាពលរដ្ឋ ............ ២
ខ. មុខរបរ ............ ២
៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ ............ ៣
ក. ទីតាំង ............ ៣
ខ. ដែននេសាទ ............ ៣
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ............ ៤
ឃ. ធនធានជលផល ............ ៤
៤. ការធ្វើនេសាទ ............ ៥
ក. អ្នកនេសាទ ............ ៥
ខ. ឧបករណ៍នេសាទ ............ ៥
គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ............ ៦
៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ............ ៦
ក.ទស្សនៈវិស័យ ............ ៦
ខ. គោលបំណងរួម ............ ៦
គ. គោលបំណងជាក់លាក់ ............ ៦
ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍ ............ ៧
ឃ.១. ធនធានជលផល និងអេកូឡូស៊ី ............ ៧
ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ ............ ៨
ឃ.៣. ការគ្រប់គ្រង ............ ១២
ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ............ ១៤
ច. យុទ្ធសាស្ត្រ ............ ១៥
តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កំពង់រទេះរយៈពេល៣ឆ្នាំ ............ ១៧
តារាងកម្មវិធីការងារប្រចាំឆ្នាំ (កក្កដា ២០១៩ - មិថុនា ២០២២) ............ ២៣

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទកំពង់រទេះ ត្រូវបានបង្កើតឡើងតាមរយៈមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ នៅឆ្នាំ២០០៩ ក្រោមការគាំទ្របច្ចេកទេស និងថវិកាដោយខណ្ឌរដ្ឋបាលជលផលក្រចេះ និងអង្គការអុស្វាមអូស្ត្រាលី (CAA/Oxfam Australia) ដោយបានរៀបចំនូវលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង បញ្ជីឈ្មោះសមាជិក និងគណៈកម្មការ រចនាសម្ព័ន្ធគ្រប់គ្រង និងផែនទីកន្លែងនេសាទសហគមន៍ច្បាស់លាស់។ បន្ទាប់មកសហគមន៍បានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយខណ្ឌរដ្ឋបាលជលផលក្រចេះលើកដំបូងនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១។ សហគមន៍នេសាទកំពង់រទេះបានចុះបញ្ជីជាផ្លូវការ និងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។ ដោយអាណត្តិរបស់គណៈកម្មការមានរយៈពេល៥ឆ្នាំ និងយោងទៅតាមភាពចាំបាច់ សហគមន៍បានរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការឡើងវិញនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៧ ដោយមានការគាំទ្របច្ចេកទេស និងថវិកាពីខណ្ឌរដ្ឋបាលជលផល និងអង្គការអភិវឌ្ឍន៍ជនបទភូមិភាគឦសាន្ត (NRD) ដែលគណៈកម្មការទើបជាប់ឆ្នោតថ្មីមានចំនួន ៩នាក់ ក្នុងនោះស្រីចំនួន ៣នាក់ និងបានជ្រើសរើសជំនួយការជាស្ត្រីចំនួន២នាក់ ដោយបានរៀបចំជារចនាសម្ព័ន្ធគ្រប់គ្រង និងបែងចែកតួនាទីភារកិច្ចទទួលខុសត្រូវតាមការឯកភាពគ្នាក្នុងចំណោមសមាជិកគណៈកម្មការទាំងអស់។ បន្ទាប់មកដោយមានការគាំទ្របច្ចេកទេស និងថវិកាពីខណ្ឌរដ្ឋបាលជលផលក្រោមគំរោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (ដំណាក់កាលទី៣) សហគមន៍នេសាទក៏បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទឡើងវិញតាមរយៈកិច្ចប្រជុំនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ ដោយសមាជិកដែលបានចុះក្នុងបញ្ជីជាផ្លូវការសរុបចំនួន១០៩នាក់ ស្រីមានចំនួន៥៦នាក់ ស្មើនឹង១០១គ្រួសារ និងបានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍តាមរយៈកិច្ចប្រជុំថ្ងៃទី១១-១២ ខែកុម្ភៈ ឆ្នាំ២០១៩ និងមហាសន្និបាតអនុម័តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនៅមានការជួបប្រទះនូវបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងមានដូចខាងក្រោម៖

- បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ីរួមមានបរិមាណត្រីថយចុះ ដាច់បាក់ច្រាំងទន្លេដោយសារភ្លៀងច្រើន និងព្រៃលិចទឹកងាប់ដោយសារបាក់ដី
- បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋរួមមានខ្វះបច្ចេកទេសដាំបន្លែនិងទីផ្សារលក់បន្លែ ខ្វះបច្ចេកទេសចិញ្ចឹមសត្វ ដូចជាគោ ក្របី មាន់ ជ្រូក និងការខ្វះទុនប្រកបមុខរបរ
- បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមានបទល្មើសនេសាទដោយប្រើឧបករណ៍ឆក់មានការកើនឡើងពីអ្នកនេសាទមកពីក្រៅ បទល្មើសមានបណ្តាញ អ្នកនេសាទល្មើសច្បាប់ប្រើប្រាស់សម្ភារទំនើបនិងប្រើទូកម៉ាស៊ីនលឿនលឿន សមាជិកសហគមន៍នេសាទនៅពុំទាន់មានការយល់ដឹង និងចូលរួមការងារសហគមន៍ឱ្យបានសស្រាក់សស្រាំ សហគមន៍នេសាទចុះល្បាតមិនទៀងទាត់ដោយសារខ្វះទូកម៉ាស៊ីន សម្ភារ និងប្រេង ហើយការសហការជាមួយអាជ្ញាធរមិនទាន់បានល្អ ព្រមទាំងមិនទាន់មានទីស្នាក់ការសហគមន៍សម្រាប់ប្រតិបត្តិការ គណៈកម្មការសហគមន៍នេសាទមិនទាន់

មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំសហគមន៍នេសាទ សមាជិកសហគមន៍នេសាទនៅតែគិតថាការងារគណៈកម្មការជាការងារបច្ចេកទេស និងជាតួនាទីរបស់បុរស ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ការងារផ្ទះ និងលក់ដូរ និងការចូលរួមរបស់ស្ត្រីក្នុងកិច្ចប្រជុំនានាមានចំនួនច្រើន ប៉ុន្តែការសម្រេចចិត្តនៅមានកម្រិត។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មានចំនួន៨០៥ នាក់ ស្រី៤០០នាក់ ក្នុងនោះជនជាតិកួយ៦២% ព្នង ៣% និង ខ្មែរ៣៥%។ ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០%។

ប្រជាពលរដ្ឋភូមិកំពង់រទេះមានស្ថានភាពដូចខាងក្រោម៖

- ចំនួនស្ត្រីមេម៉ាយមាន ២៥ នាក់
- ចំនួនជនពិការមាន៨ នាក់ ស្រី៤ នាក់
- ចំនួនចាស់ជរាមាន២៥ នាក់ ស្រី១៤ នាក់
- ចំនួនកុមារកំព្រាមាន២៥ នាក់ ស្រី១៣ នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃមាន៣ នាក់ ស្រី២ នាក់
- កម្រិតសិក្សាអប់រំរួមមានអ្នកមិនចេះអក្សរមានចំនួន៣០ នាក់ ស្រី១៣ នាក់ បឋមសិក្សាចំនួន១៧៥ នាក់ ស្រី៨៤ នាក់ មធ្យមសិក្សាចំនួន៤២ នាក់ ស្រី២០ នាក់ និងឧត្តមសិក្សាចំនួន២នាក់ ស្រី១នាក់។

### ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន១៦៥ គ្រួសារ (៩២%)
- ធ្វើស្រែវស្សាចំនួន១៦៧ គ្រួសារ ទំហំ១៨៤ ហិកតា
- ដាំបន្លែចំនួន៤០ គ្រួសារ
- ធ្វើចំការចំនួន៣០ គ្រួសារ ទំហំ៥២ ហិកតា
- ធ្វើជាងផ្ទះចំនួន៤ គ្រួសារ
- សិប្បកម្មម្ហូក កញ្ចើ កញ្ច្រែង ល្អីចំនួន៣០ គ្រួសារ
- លក់ដូរចាប់ហួយចំនួន៧ គ្រួសារ។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

ក. ទីតាំង

កន្លែងនេសាទសហគមន៍ភូមិកំពង់រទេះ ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ស្ថិតនៅតាមដងទន្លេមេគង្គមានទំហំ ៥២៧ ហិកតា និងមាននិយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងភូមិអូរក្រសាមង ឃុំបឹងចារ និង ភូមិកំពង់ភ្នៅ ឃុំកោះខ្នែរ ស្រុកសំបូរ ខេត្តក្រចេះ
- ខាងត្បូងទល់នឹងភូមិកោះដំបង និង ភូមិដំរ៉ែ ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ
- ខាងកើតទល់នឹងកោះប្រែង ភូមិជើងពាត ឃុំកោះខ្នែរ ស្រុកសំបូរ ខេត្តក្រចេះ
- ខាងលិចទល់នឹងកោះរងាវ ភូមិអំពិលទឹក ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ។

ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ភូមិកំពង់រទេះ ស្ថិតនៅតាមដងទន្លេមេគង្គ មានកោះ និងព្រៃលិចទឹកដុះរាយនៅតាមមាត់ច្រាំងទន្លេ និងនៅតាមកោះ ដែលមានអន្លង់ចំនួន៧ អូរចំនួន១៧ និងកោះចំនួន៤ គឺ៖

| | | |
|---|---|---|
| - អន្លង់ក្បាលកោះថ្ម | ទំហំ ០,២៥ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់នាងស្អាង | ទំហំ ០,១២ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់កោះប្រែង | ទំហំ ៣០ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់កាច់ច្រវ៉ាក់ | ទំហំ ០,១២ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់ស្ពុមតូច | ទំហំ ០,៣៥ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់ស្ពុមធំ | ទំហំ ០,៨៥ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់លោកតាសាកង្កែប | ទំហំ ២៥ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អូរប្រហ៊ុត | ប្រវែង ២.៥០០ ម៉ែត្រ | មានទឹកពីខែឧសភាដល់តុលា |
| - អូរតាអ៊ីម | ប្រវែង ២០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់ខែតុលា |
| - អូរតាកែម | ប្រវែង ៥០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់ខែតុលា |
| - អូរសូភាគ | ប្រវែង ២០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់ខែតុលា |
| - អូរខូត | ប្រវែង ១៥០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់ខែតុលា |
| - អូរតាខាន់ | ប្រវែង ១០០ ម៉ែត្រ | មានទឹកពីខែសីហាដល់ខែតុលា |
| - អូរតាពាន | ប្រវែង ១.០០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់ខែតុលា |
| - អូរនាងស្អាង | ប្រវែង ២៥០ ម៉ែត្រ | មានទឹកពីខែមិថុនាដល់ខែតុលា |
| - អូរតាឌិន | ប្រវែង ១០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់ខែតុលា |
| - អូរម៉ៅម៉ាត | ប្រវែង ២.០០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់ខែតុលា |

| | | |
|---|---|---|
| - អូរអ៊្សីទ្វី | ប្រវែង ៨០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់ខែតុលា |
| - អូរតាកែវ | ប្រវែង ១.០០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់ខែតុលា |
| - អូរតារិន | ប្រវែង ១០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់ខែតុលា |
| - អូរតាគា | ប្រវែង ២០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់ខែតុលា |
| - អូរតាណយ | ប្រវែង ២.០០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់ខែតុលា |
| - អូរតាឈុន | ប្រវែង ២០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់ខែតុលា |
| - អូរតាហាត | ប្រវែង ២០០ ម៉ែត្រ | មានទឹកពីខែកក្កដាដល់ខែតុលា |
| - កោះក្រវាញ | ទំហំ ៧៣ ហិកតា | |
| - កោះរកោរ | ទំហំ ០,២០ ហិកតា | |
| - កោះតាជ្រឹង | ទំហំ ០,១០ ហិកតា | |
| - កោះទន្សាយ | ទំហំ ១,២០ ហិកតា។ | |

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

អន្លង់លោកតាសាកង្កែប ទំហំ២៥ហិកតា (បណ្តោយ ២.៥០០ម៉ែត្រ និងទទឹង ១០០ម៉ែត្រ) និងអន្លង់កោះប្រែង ទំហំ៣០ហិកតា (បណ្តោយ១.០០០ម៉ែត្រ និងទទឹង៣០០ម៉ែត្រ) ជាតំបន់ដែលមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ តាមការសម្រេចរបស់មហាសន្និបាត។

ឃ. ធនធានជលផល

ឃ.១. ប្រភេទត្រី ៖

ត្រីខ្យា ត្រីឆ្លាំង ត្រីតានេល ត្រីឆ្កោក ត្រីត្រសក់ ត្រីក្អែក ត្រីក្តី ត្រីក្រាយ ត្រីឆ្តោ ត្រីរ៉ស់ ត្រីសណ្តាយ ត្រីក្លាំងហាយ ត្រីប្រា ត្រីកែស ត្រីប្រាកណ្តុរ ត្រីពោធិ៍ ត្រីព្រលូង ត្រីដំរី ត្រីផ្ទក់ ត្រីឆ្លូញ ត្រីខ្ទឹង ត្រីរៀល ត្រីក្រឡង់ ត្រីកញ្ចុះ ត្រីគ្រំ ត្រីក្រាញ់ ត្រីកន្ត្រប់ ត្រីចេក ត្រីសារិកាកែវ ត្រីឆ្ពិន ត្រីកាហែ ត្រីប្រកែង ត្រីចង្វារ ត្រីអណ្តែង ត្រីស្លឹកឫស្សី ត្រីកំភ្លាវ ត្រីតាអោន ត្រីបបែល ត្រីលលកស ត្រីស្ទក់ ត្រីខ្មាន់ ត្រីក្រុស ត្រីកញ្រ្ជូក ត្រីអាចម៍កុក ត្រីកំបុតច្រមុះ ត្រីក្របី ត្រីកែ ត្រីឈ្មៀត ត្រីកំពត ត្រីផ្ទោង អន្ទង់ ត្រីខ្លា ត្រីប្រម៉ា ត្រីរាហ៊ូ ត្រីអណ្តាតឆ្កែ ត្រីស្លាត ត្រីននោងល្វីង ត្រីកន្ត្រងប្រេង ត្រីរមាស ត្រីតាយ៉ូ ត្រីខ្សាច់ ត្រីឆ្មុកដប ត្រីលេញ ត្រីផ្កាគ ត្រីអាចម៍ស្វា ត្រីផ្កក់ ត្រីខ្សាន ត្រីពុកមាត់ឆ្មា ត្រីកន្ត្រប់ជាដើម។

ឃ.២. ប្រភេទវារីសត្វ ៖

អណ្តើក កន្ធាយ និង ល្មិច។

ឃ.៣. ព្រៃលិចទឹក និងរុក្ខជាតិ

ដើមរ៉ៃ ដើមអញ្ចេង ដើមទន្លា ដើមត្រស់ ដើមរាំង ដើមប្រមៀ ដើមក្តុល ដើមត្រែង ដើមស្លត ដើមបបុស ដើមឆ្អឹងពស់ ដើមបន្លាយួន ដើមឱជ្រឹង លាជផ្ទុះ ដើមប៉ាង ព្រីងទឹក មៀនទឹក និង ដើមក្របៅជាដើម។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៩២ នាក់ ស្រី២៣ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទក្នុងសហគមន៍មានចំនួន៧៣ នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍ចំនួន៦០ នាក់ ស្រី២០ នាក់។

### ខ. ឧបករណ៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ ឧបករណ៍នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាងក្រៅ ភូមិ | |
| មង | ត្បូង | ៧៥ | ២៥ | ១៥០ | ក្រឡា ០,០២ - ០,០៩ម | ក្រឡា ០,០២ - ០,០៩ម | ក្រឡា០,០៧ - ០,០១៥ម | មករា - ធ្នូ |
| លប | លប | ៨០ | ៤៥ | ៣០០ | មុខ១,២ម បណ្ដោយ២ម | មុខ១,២ម បណ្ដោយ ២ម | មុខ១,២ម បណ្ដោយ២ម | ឧសភា - វិច្ឆិកា |
| ចាន់ | ចាន់ | ៦០ | ៦៥ | | មុខ០,៣ម បណ្ដោយ ១,២ម | មុខ០,៣ម បណ្ដោយ ១,២ម | | ឧសភា - វិច្ឆិកា |
| សន្ទូច រនង | សាង | ៧០ | ៨០ | ៧០ | ១០០ផ្លែ លេខ៥ -៧ | ១០០ផ្លែ លេខ៥- ៧ | ១០០ផ្លែ លេខ ៩ -១២ | មករា - ធ្នូ |
| បង្កៃ | ផ្លែ | ៣០០ | ២០០ | ៧៥ | លេខ ៥-៧ | លេខ ៥-៧ | លេខ ៥- ៧ | កក្កដា - វិច្ឆិកា |
| បង្កង | ផ្លែ | ៤០០ | ៣០០ | ៧៥ | លេខ ៥-៧ | លេខ ៥-៧ | លេខ១០-១៥ | ឧសភា - ធ្នូ |
| សំណាញ់ | វង់ | ២០ | ៣០ | ៧ | ប្រវែ៥,៥ម ក្រឡា ០,០១៨ម - ០,០២៥ម | ប្រវែ៥,៥ម ក្រឡា ០,០១៨ម -០,០២៥ម | ប្រវែង៤,៥ម ក្រឡា ០,០១៥ ម | មករា - ធ្នូ |
| ទ្រូ | ទ្រូ | ៥ | ១៥ | | មុខ០,២ម បណ្ដោយ ០,៨ម | មុខ០,២ម បណ្ដោយ ០,៨ម | | មិថុនា - កញ្ញា |

ប្រភេទទូកកាណូត

| ប្រភេទទូកកាណូត | ចំនួន (ទូក) | | | ចំណុះ(គីឡូក្រាម) | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកអុំ/ចែវ | ៤ | ១ | | ២០០-៣០០ | ២០០-៣០០ | | | | |
| ទូកមានម៉ាស៊ីន | ៧៩ | ៤៦ | ៤៥ | ៤០០-៧០០ | ៤០០-៧០០ | ៤០០-១.០០០ | ៦,៥-១៨ | ៦,៥-១៨ | ១៣-១៨ |

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ (គីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៣៧៩,៣០ | ៥៨៦,៨៦ | ៩៦៦,១៦ |

## ៥. ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍

ក. ទស្សនៈវិស័យ

សហគមន៍នេសាទ ភូមិកំពង់រទេះ មានទស្សនវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកប ដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោមៈ

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ។

គ. គោលបំណងជាក់លាក់

- ការពារ និងដាំព្រៃលិចទឹកជាជម្រកត្រីនៅតាមច្រាំងទន្លេ
- បង្កើនជម្រើសមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ តាមរយៈការចិញ្ចឹមសត្វ ត្រី ដាំបន្លែ និងមានទីផ្សារសម្រាប់កសិផល
- កាត់បន្ថយបទល្មើសនេសាទ តាមរយៈការផ្សព្វផ្សាយ និងចុះល្បាត ដោយមានកិច្ចសហការជាមួយ អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ។

ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍

ឃ.១. ធនធានជលផល និងអេកូឡូស៊ី

ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ការប៉ាន់ស្មានថវិកា (ដុល្លារ) |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ / ប្រវែង | ចំនួន | |
| ១. នៅតាមដងទន្លេមេគង្គនៅខាងក្រៅអន្លង់អភិរក្សសហគមន៍ | មករា - ធ្នូ | សំណាញ់ | ប្រវែង ៥,៥ ម ក្រឡា ១,៨ - ២,៥ សម | ៥៧ វង់ | ១៥០-(៥០/ឆ្នាំសម្រាប់ការងារផ្សព្វផ្សាយ) |
| | មករា - ធ្នូ | សន្ទូចរនង | ផ្លែលេខ ៥ - ១២ | ២២០ សាង (១០០ផ្លែ/សាង) | |
| | កក្កដា - វិច្ឆិកា | បង្គៃ | ផ្លែលេខ ៥ - ៧ | ៥៧៥ ផ្លែ | |
| | ឧសភា - ធ្នូ | បង្កង | ផ្លែលេខ ៥ - ១៥ | ៧៧៥ ផ្លែ | |
| | ឧសភា - វិច្ឆិកា | លប | មុខ១,២ម បណ្តោយ ២ម | ៤២៥ លប | |
| | ឧសភា - វិច្ឆិកា | ចាន់ | មុខ០,៣ម បណ្តោយ១,២ម | ១២៥ ចាន់ | |
| | មិថុនា - កញ្ញា | ទ្រូ | មុខ០,២ម បណ្តោយ០,៨ម | ២០ ទ្រូ | |
| | មករា - ធ្នូ | មង | ក្រឡា ២ - ៩សម | ២៥០ ត្បូង | |

ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ / ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់លោកតាសាកង្កែប | ២៥ ហិកតា | • ត្រីគ្រប់ប្រភេទ<br>• សត្វទឹកគ្រប់ប្រភេទ<br>• ព្រៃលិចទឹកគ្រប់ប្រភេទ | • ដាក់ពោង និងស្លាកសញ្ញាតាមអន្លង់<br>• តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស<br>• លែងកូនត្រីពូជ | • ដាក់ពោង/ស្លាក (៨x ២០០=១.៦០០)<br>• តម្លើងផ្ទាំងផ្សព្វផ្សាយ (២x២០០=៤០០)<br>• លែងកូនត្រីពូជ (៣ លើកx៥០០=១.៥០០) | កក្កដា ២០១៩ | មិថុនា ២០២២ |
| អន្លង់កោះប្រែង | ៣០ ហិកតា | | | | | |

### ឃ.១.៣. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ / ទីតាំង | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ក្បាលក្រវាញ ខាងលិចលោកតាសាកង្កែប ខាងកើតលោកតាសាកង្កែប កន្ទុយកោះគ្រើង | បោះបង្គោលព្រំប្រទល់កន្លែងនេសាទលើគោក | ៤ បង្គោល | ១.២០០ (៤x៣០០) | កក្កដា ២០១៩ | ធ្នូ ២០១៩ |
| សាលារៀនបឹងស្មៀត សាលារៀនកំពង់រទេះ | រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ (ឱ្យស្ត្រីនិងបុរសជាគណៈកម្មាការសហគមន៍នេសាទចូលរួមសម្រេចចិត្តក្នុងការកំណត់ទីតាំងបោះបង្គោលព្រំប្រទល់) | ២ ផ្ទាំង | ៦០០ (២x៣០០) | តុលា ២០១៩ | ធ្នូ ២០១៩ |

### ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះទីតាំង | ទំហំ (ហិកតា) | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| តាមច្រាំងទន្លេ និងមាត់អូរ | តាមច្រាំងទន្លេនៅទន្ទឹម ក្បាលកោះព្រៀល ក្បាលកោះក្រវាញ | ព្រៃលិចទឹកដែលត្រូវការពាររួមមាន៖ គ្រៃង រ៉ៃ ត្រស់ រាំងទន្លា | • ប្រជុំផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក (ស្ត្រីជាគណៈកម្មការសហគមន៍នេសាទចូលរួមផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក ការពារព្រៃលិចទឹក និងដាក់ស្លាកសញ្ញាសម្គាល់)<br>• ការពារព្រៃលិចទឹកដែលមានស្រាប់<br>• ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក និងស្លាកសញ្ញាសម្គាល់<br>• ដាំព្រៃលិចទឹក<br>• ចុះល្បាតជាប្រចាំ | ៣០០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ

### ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៦០គ្រួសារ | ៣.០០០<br>(៦០០ក្បាលx៥) | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមទាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមទាជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៥គ្រួសារ | ២៥០<br>(៥០ក្បាលx៥) | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមគោជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៥០គ្រួសារ | ១៥.០០០<br>(៥០ក្បាលx៣០០) | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមក្របីតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមក្របីជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៥០គ្រួសារ | ១៥.០០០<br>(៥០ក្បាលx៣០០) | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាល បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ២០គ្រួសារ | ២.០០០<br>(៤០ក្បាលx៥០) | កក្កដា ២០១៩ | មិថុនា ២០២២ |
| សួនបន្លែតាមលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសធ្វើសួន បន្លែជាគ្រួសារ<br>• ចែកគ្រាប់ពូជ<br>• តាមដានត្រួតពិនិត្យ | បន្លែ ៥មុខ៖ (ស្ពៃ ត្រកួន ននោង សណ្តែកកួរ ត្រប់វែង ត្រសក់) | ១៥ គ្រួសារ | ៧៥០<br>(១៥គ្រួសារx៥០) | កក្កដា ២០១៩ | មិថុនា ២០២២ |
| បណ្តុះផ្សិត | • ជ្រើសរើសគ្រួសារកសិករ | ផ្សិតចំបើង | ១៥ គ្រួសារ | ៧៥០ | កក្កដា | មិថុនា |

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| | ស្ម័គ្រចិត្ត<br>• បណ្ដុះបណ្ដាលបច្ចេកទេសបណ្ដុះផ្សិត និងធ្វើមេផ្សិត<br>• អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ | និង ផ្សិតអំបោះ | | (១៥គ្រួសារx៥០) | ២០១៩ | ២០២២ |
| ធ្វើមេផ្សិត | • បណ្ដុះបណ្ដាលបច្ចេកទេសធ្វើមេផ្សិត | ផ្សិតចំបើង និង ផ្សិតអំបោះ | ១ គ្រួសារ | ៣០០<br>(១គ្រួសារx៣០០) | កក្កដា ២០១៩ | មិថុនា ២០២២ |
| ដាំដំណាំហូបផ្លែ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្ដុះបណ្ដាលបច្ចេកទេសដាំដំណាំហូបផ្លែជាគ្រួសារ<br>• ចែកពូជ<br>• តាមដានត្រួតពិនិត្យ | ប្រភេទដំណាំៈ ដូង ក្រអូប ក្រូចថ្លុងផ្អែម ក្រូចពោធិសាត់ | ១០ គ្រួសារ | ៣.០០០<br>(១០គ្រួសារx ៣០០) | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីអណ្ដែងក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>• បណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹមត្រីអណ្ដែងជាលក្ខណៈគ្រួសារ<br>• រៀបចំស្រះចិញ្ចឹមត្រី<br>• ផ្ដល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ស្រះប្លាស្ទិក ឬអាងស៊ីម៉ងចំនួន០១ក្នុងមួយគ្រួសារ(ទំហំ ៤មx៦មx១ម) | ១០ គ្រួសារ | ៥.០០០<br>(១០គ្រួសារx ៥០០) | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់

ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ ត្រូវបានរៀបចំដូចក្នុងតារាងខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់ចំនួន ៣ ក្រុមបន្ថែម | • ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍<br>• ជ្រើសរើសអ្នកទទួលផល<br>• បោះឆ្នោតជ្រើសរើសប្រធានក្រុម<br>• បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• ផ្តល់ទុនដល់ក្រុម<br>• តាមដាន និង ត្រួតពិនិត្យ | ៩០០<br>(៣ក្រុម×៣០០) | កក្កដា ២០១៩ | មិថុនា ២០២២ |
| ពង្រឹងក្រុមសន្សំប្រាក់ដែលមានស្រាប់ ៣ ក្រុម | • ផ្សព្វផ្សាយទស្សនៈទានក្រុមសន្សំដល់សហគមន៍<br>• ជ្រើសរើសអ្នកទទួលផលបន្ថែម<br>• ពិនិត្យ និងកែសម្រួលគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• ផ្តល់ទុនបន្ថែមដល់ក្រុម<br>• តាមដាន និង ត្រួតពិនិត្យ | ៦០០<br>(៣ក្រុម×២០០) | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| សាងសង់ផ្លូវលំថ្មីបន្តពីសាលារៀនកំពង់រទេះទៅដល់ក្បាលកោះឆ្នោតប្រវែង៧គម ដែលត្រូវដាក់លូ៦កន្លែង | ១ ខ្សែ | ៧៩.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ដាក់លូទោលកាត់ផ្លូវអង្កត់ផ្ចិត៨០០មម និងចាក់ដីប្រវែង៣០ម កម្រាស់២ម | ៧កង់ | ៥.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សាងសង់បង្គន់អនាម័យតាមគ្រួសារបន្ថែម | ១០៧ បង្គន់ | ២១.៤០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.៥. ផែនការពង្រឹងសកម្មភាពសហគមន៍នៃសាទទេសចរណ៍ធម្មជាតិ

ផែនការពង្រឹងសកម្មភាពសហគមន៍នៃសាទទេសចរណ៍ធម្មជាតិ ត្រូវបានរៀបចំខាងក្រោម ៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| រៀបចំបង្កើតតំបន់ទេសចរណ៍នៅជ្រូវចំហុង និងក្បាលក្រវាញ និងរៀបចំវគ្គបណ្តុះបណ្តាលអំពីបដិសណ្ឋារកិច្ច | ៣ វគ្គ<br>(១វគ្គ/ឆ្នាំ) | ៣០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| តម្លើងផ្ទាំងផ្សព្វផ្សាយសកម្មភាពទេសចរណ៍ធម្មជាតិ | ១ ផ្ទាំង | ៣០០ | មីនា ២០២០ | មីនា ២០២០ |

ឃ.៣. ការគ្រប់គ្រង

ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង | | ១០ដង/១ខែ | ៩.០០០ (១០ដងx១២ខែx៣ x២៥) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ផ្ដល់សម្ភារល្បាត១ ឈុត | អាវពោង | ១៥ អាវ | ១.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | អាវភ្លៀង | ១៥ អាវ | | | |
| | គោមបំភ្លឺពាក់ក្បាល | ៦ គោម | | | |
| | វិទ្យុទាក់ទង | ៣ គ្រឿង | | | |
| | កែវយឺត | ៣ គ្រឿង | | | |
| | ម៉ាស៊ីនថត | ១ គ្រឿង | | | |
| | អង្រឹង | ១៥ | | | |
| | តង់គ្របទូក ៤មគុណ៦ម | ៣ ផ្ទាំង | | | |
| | សម្ភារត្រួតពិនិត្យទឹក | ១ គ្រឿង | | | |
| | ស្លាបចក្រ | ១៨ គ្រឿង | | | |
| | សោរសម្រាប់ជួសជុលទូក | ១សម្រាប់ | | | |
| | សោរច្រវាក់ចាក់ទូក | ៣ ឈុត | | | |
| | អាវកាក់ | ១៥ អាវ | | | |
| ទិញទូកស្ពាច់ម៉ាស៊ីន | | ២ គ្រឿង | ៣.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ប្រេងសម្រាប់ល្បាត | | ២០០ លីត្រ/ខែ | ៧.២០០ (២០០លីត្រx៣៦ខែ) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សេវាជួសជុលនិងថែទាំទូក និងម៉ាស៊ីន | | ២ដង/ឆ្នាំ | ៦០០ (៦ដងx១០០) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សាងសង់ទីស្នាក់ការសហគមន៍ (ដីសាលាឆទាន) | | ១ កន្លែង | ៣.០០០ | កក្កដា ២០១៩ | កញ្ញា ២០១៩ |

### ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ៣៦០ (៣៦ដងx១០) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | ៣៦០ (៣៦ដងx១០) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |
| បណ្ដុះបណ្ដាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាល របាយការណ៍ និងរៀបចំទុកដាក់ឯកសារ | ១លើក/១ឆ្នាំ | ៦០ (៣លើកx២០) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |
| បណ្ដុះបណ្ដាលអំពីការដោះស្រាយទំនាស់ | ១លើក/១ឆ្នាំ | ៦០ (៣លើកx២០) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |
| បណ្ដុះបណ្ដាលអំពីភាពជាអ្នកដឹកនាំ | ១លើក/១ឆ្នាំ | ៦០ (៣លើកx២០) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |
| បណ្ដុះបណ្ដាលអំពីការរៀបចំផែនការសកម្មភាពការងារ | ១លើក/១ឆ្នាំ | ៦០ (៣លើកx២០) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |
| បណ្ដុះបណ្ដាលអំពីការកត់ត្រាចំណាយចំណូល | ១លើក/១ឆ្នាំ | ៦០ (៣លើកx២០) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |
| បណ្ដុះបណ្ដាលអំពីការសរសេរសំណើថវិកា | ១លើក/១ឆ្នាំ | ៦០ (៣លើកx២០) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោម៖

| ផែនការ | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| បង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃ ក្នុងសហគមន៍នេសាទ | ២ដង/ឆ្នាំ | ១៥០ (៦ដងx២៥) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ | ១ដង/ឆ្នាំ | ៧៥ (៣ដងx២៥) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយដែននេសាទនិងកន្លែងអភិរក្សរបស់សហគមន៍ | ១ដង/ឆ្នាំ | ៧៥ (៣ដងx២៥) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់សមាជិកភាពនិងភាគទានប្រចាំឆ្នាំ | ១ដង/ឆ្នាំ | ៣០ (៣ដងx១០) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ | ១ដង/ឆ្នាំ | ៧៥ (៣ដងx២៥) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |

| | | | | | |
|---|---|---|---|---|---|
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ | ៣០០ (៣ដងx១០០) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រី ក្នុងសហគមន៍នេសាទ និងការងារផ្ទះ: សមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ | ៧៥ (៣ដងx២៥) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ១៥០ (៣លើកx៥០) ៣ឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការសហគមន៍នេសាទ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៣០ (៣លើកx១០) ៣ឆ្នាំ | | | គណៈកម្មការសហគមន៍នេសាទ |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានសមាជិកភាពសហគមន៍នេសាទ | ចុះប្រមូលប្រាក់សមាជិកភាព | កក្កដា ២០១៩ | មិថុនា ២០២២ | ១៣,៦៣ | ៥០០ រៀល/នាក់ (១០៩នាក់) |
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | | | ៣៧៨,៧៥ | ៥.០០០រៀល/គ្រួសារក្នុងមួយឆ្នាំ (១០១ គ្រួសារ) |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការដៃគូ) | • ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>•សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | | | ១៨៤.៩៦៨ | -ចំណាយ ១៨៥.៣៦០ដុល្លារ<br>-ចំណូល ៣៩២,៣៨ដុល្លារ |

### ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចតារាងខាងក្រោម៖

| សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ១២ដងx១០= ១២០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការ សហគមន៍នេសាទ |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពី ស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិច | ៣ដងx២០០= ៦០០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការ សហគមន៍នេសាទ |

## ច. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ
- ជ្រើសរើសស្ត្រីមេគ្រួសារ ជាសមាជិកចំនួនយ៉ាងតិច៧% ចូលរួមក្នុងសកម្មភាពទ្រទ្រង់ជីវភាពរស់នៅ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទចូលរួមយ៉ាងតិច ៤០% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាព ទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- កម្មករគ្មានជំនាញជាស្ត្រីជាសមាជិកសហគមន៍នេសាទ៤០%ចូលរួមសកម្មភាពហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

- អញ្ជើញស្ត្រីមេគ្រួសារ ស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិចជាសមាជិកសហគមន៍នេសាទ ចូលរួមប្រជុំ និងចូលរួមសកម្មភាពនានា និងចូលជាគណៈកម្មការរបស់សហគមន៍នេសាទ
- ជ្រើសរើសស្ត្រីជាសមាជិកសហគមន៍នេសាទ ៥០% ចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព
